# ទីក្រុង OAKLAND

LIONEL J. WILSON BLDG • 250 FRANK H. OGAWA PLAZA, SUITE 1320 • OAKLAND, CA 94612-2093

នាយកដ្ឋានហិរញ្ញវត្ថុ, ការិយាល័យចំណូល និងសារពើពន្ធ BTU (510) 238-3704
Business Tax Unit (BTU) TDD RELAY 711

ថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2022

ឈ្មោះក្រុមហ៊ុនអាជីវកម្ម
ជូនចំពោះ
អាសយដ្ឋានប្រៃសណីយ៍
ទីក្រុង, រដ្ឋ, លេខកូដតំបន់ផ្ញើតាមប្រៃសណីយ៍

សូមគោរពម្ចាស់អាជីវកម្ម!

លិខិតជូនដំណឹងនេះមានបំណងជម្រាបជូនលោកអ្នកអំពីការផ្លាស់ប្តូរសំខាន់ៗ ដែលនឹងប៉ះពាល់ដល់ការដាក់លិខិតប្រកាសពន្ធ និងទូទាត់ពន្ធលើអាជ្ញាបណ្ណអាជីវកម្មប្រចាំឆ្នាំរបស់លោកអ្នក គិតចាប់ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2023 តទៅ។ លទ្ធផលដំបូងបង្ហាញថា អ្នកបោះឆ្នោតនៅក្នុងទីក្រុង Oakland បានអនុវត្តលើ "វិធានការ T" ដោយលុបចោល និងជំនួសជំពូកទី 5.04 នៃក្រមក្រុង Oakland ជាមួយនឹងតារាងពន្ធថ្មីលើអាជីវកម្មដែលកើនឡើងតាមកម្រិត។ ខោនធី Alameda ត្រូវបានរំពឹងថានឹងបញ្ជាក់លទ្ធផលបោះឆ្នោតត្រឹមថ្ងៃទី 16 ខែធ្នូ ឆ្នាំ 2022។

"វិធានការ T" បង្កើតអត្រាពន្ធដែលកើនឡើងតាមកម្រិតថ្នាក់ រួមជាមួយនឹងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតដែលនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2023។

## ការផ្លាស់ប្តូរសំខាន់ៗ៖

- **<u>តារាងពន្ធ៖</u>** ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2023 តារាងពន្ធបច្ចុប្បន្ននឹងផ្លាស់ប្តូរទៅជាតារាងអត្រាពន្ធអាជីវកម្មដែលកើនឡើង។ តារាងពន្ធដែលកើនឡើងកំណត់អត្រាខ្ពស់លើអាជីវកម្មដែលរកប្រាក់ចំណូលដុលបានច្រើន។

- **<u>កាលបរិច្ឆេទកំណត់៖</u>** ការប្រកាសពន្ធអាជីវកម្មប្រចាំឆ្នាំ 2023 និងការបង់ពន្ធអាជីវកម្មត្រូវផុតកំណត់ត្រឹម ឬមុន**ថ្ងៃទី 1 ខែមីនា ឆ្នាំ** 2023 សម្រាប់បុគ្គលទាំងអស់ដែលចូលរួមក្នុងសកម្មភាពអាជីវកម្មណាមួយ រួមទាំងសកម្មភាពអាជីវកម្មសេវាជួលផងដែរ។ ការបង់ពន្ធអាជីវកម្ម ឬចំណែកប្រាក់ពន្ធមិនបានបង់ត្រឹម ឬមុន**ថ្ងៃទី 1 ខែមីនា ឆ្នាំ** 2023* នឹងត្រូវប្រកាសថាហួសកំណត់ពេលបង់ ហើយត្រូវបង់ប្រាក់ពិន័យយឺតយ៉ាវដូចខាងក្រោម។

- **<u>ការពិន័យ៖</u>**
  ដប់ភាគរយ **(10%)** នៃចំនួនទឹកប្រាក់សរុបដែលនៅតែហួសកំណត់ពេលបង់ ចាប់ពី**ថ្ងៃទី 2 ខែមីនា ឆ្នាំ 2023 បូកនឹង**

ម្ភៃប្រាំភាគរយ **(25%)** នៃចំនួនទឹកប្រាក់សរុបដែលនៅតែហួសកំណត់ពេលបង់ ចាប់ពី**ថ្ងៃទី 2 ខែឧសភា ឆ្នាំ 2023**

- <u>**ការប្រាក់៖**</u>
  មួយភាគរយ (1%) ក្នុងមួយខែ ឬចំណែកនៃចំនួនទឹកប្រាក់នៃការមិនបានបង់ រួមទាំងប្រាក់ពិន័យ ចាប់ពីថ្ងៃដែលការមិនបង់ប្រាក់ដំបូងហួសកំណត់ពេលបង់លើកដំបូងរហូតដល់បានទូទាត់រួច។

**ករណីលើកលែង៖**

- <u>**លែងមានទៀតហើយ - ការលើកលែងចំពោះអាជីវកម្មខ្នាតតូច**</u>
  "សហគ្រាសអាជីវកម្មខ្នាតតូច" លែងត្រូវបានលើកលែងពីការបង់ពន្ធអាជីវកម្មទៀតហើយ។

- <u>**លែងមានទៀតហើយ - ការលើកលែងរយៈពេលប្រាំឆ្នាំ - អគារថ្មី ឬកែកុន**</u>
  អគារថ្មីទាំងអស់ និងអគារទាំងនោះដែលបានបញ្ចប់ការកែកុនច្រើនបន្ទាប់ពីថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2023 នឹងមិនមានសិទ្ធិទទួលបានការលើកលែងនោះទេ។

- <u>**ការលើកលែងចំពោះអចលនទ្រព្យជួលដែលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិ**</u>
  ម្ចាស់កម្មសិទ្ធិនៃផ្ទះសម្រាប់រស់នៅពីរគ្រួសារ ផ្ទះសម្រាប់រស់នៅបីគ្រួសារ ឬផ្ទះសម្រាប់រស់នៅតែមួយគ្រួសារដែលមានបន្ទប់ស្នាក់នៅមួយឬពីរ (ADUs) នឹងទទួលបានការលើកលែងពន្ធក្នុងករណី៖

  i. ម្ចាស់បច្ចុប្បន្នរស់នៅក្នុងបន្ទប់ស្នាក់នៅមួយក្នុងចំណោមបន្ទប់ស្នាក់នៅផ្សេងទៀត ជាកន្លែងរស់នៅចម្បងរបស់ពួកគេ ហើយបានទទួលការលើកលែងពន្ធលើអចលនទ្រព្យសម្រាប់ម្ចាស់ផ្ទះ ចំពោះការវាយតម្លៃអចលនទ្រព្យនៅក្នុងខោនធីរបស់ពួកគេក្រោមក្រមចំណូល និងពន្ធដារនៃរដ្ឋ California ផ្នែកទី 218 **និង**

  ii. ម្ចាស់កម្មសិទ្ធិបានកាន់កាប់អចលនទ្រព្យ និងរស់នៅក្នុងបន្ទប់ស្នាក់នៅមួយក្នុងចំណោមបន្ទប់ស្នាក់ផ្សេងទៀតជាកន្លែងរស់នៅចម្បងរបស់ពួកគេ ក្នុងរយៈពេលយ៉ាងហោចណាស់មួយ (1) ឆ្នាំ មុនការដាក់ពាក្យសុំលើកលែងពន្ធនេះ **និង**

  iii. សម្រាប់ផ្ទះសម្រាប់រស់នៅពីរគ្រួសារ និងផ្ទះសម្រាប់រស់នៅបីគ្រួសារ បន្ទាប់ជួលគឺជា "បន្ទប់ស្ថិតក្រោមការរ៉ាប់រង" ដូចដែលបានកំណត់នៅក្នុងក្រមទីក្រុង Oakland ផ្នែកទី 8.22.020 **និង**

  iv. ប្រាក់ចំណូលគ្រួសារសរុបរបស់ម្ចាស់ពីប្រភពទាំងអស់គឺតិចជាង ឬស្មើនឹង 150% នៃប្រាក់ចំណូលមធ្យមក្នុងតំបន់ (AMI) **និង**

  v. ម្ចាស់កម្មសិទ្ធិមិនមានផលប្រយោជន៍នៃកម្មសិទ្ធិនៃអចលនទ្រព្យលំនៅឋានប្រភេទជួលផ្សេងទៀតនៅក្នុងទីក្រុង Oakland ទេ។

**ការផ្លាស់ប្តូរផ្សេងទៀត៖**

- <u>**អង្គភាពពាក់ព័ន្ធ និងវិញ្ញាបនបត្រដើម៖**</u>
  *អង្គភាពពាក់ព័ន្ធដែលចូលរួមក្នុងខ្សែសង្វាក់សកម្មភាពអាជីវកម្មទូទៅដូចគ្នា។* បុគ្គលទាំងអស់ និងអង្គភាពពាក់ព័ន្ធរបស់ពួកគេដែលបង្កើតចំណូលដុលដែលអាចរាប់បញ្ចូលជាបន្ទុករបស់ទីក្រុងតាមរយៈការចូលរួមក្នុងសកម្មភាពអាជីវកម្មប្រភេទស្រដៀងគ្នាពីគ្រឹះស្ថានសាខា ឬកន្លែងប្រកបអាជីវកម្មដាច់ដោយឡែក ត្រូវប្រមូលចំណូលដុលប្រចាំឆ្នាំដែលអាចអនុវត្តបានពីបុគ្គលទាំងអស់ និងអង្គភាពពាក់ព័ន្ធ ដោយស្ថិតនៅក្រោមវិញ្ញាបនបត្រដើម មុនពេលអនុវត្តអត្រា និងដាក់លិខិតប្រកាសពន្ធ<u>**មួយ**</u>។

- **<u>ចំណូលដុលប៉ាន់ស្មានសម្រាប់ឆ្នាំដំបូង៖</u>**
  *អាជីវកម្មដែលទើបបង្កើតថ្មីក្នុងឆ្នាំ 2023។* គ្រប់បុគ្គលដែលដាក់ពាក្យសុំវិញ្ញាបនបត្រពន្ធអាជីវកម្មដំបូងសម្រាប់អាជីវកម្មដែលទើបបង្កើតថ្មីត្រូវផ្ដល់ចំនួនប្រាក់ចំណូលដុលប៉ាន់ស្មានដែលរំពឹងទុកសម្រាប់រយៈពេលចាប់ពីការចាប់ផ្ដើមសកម្មភាពអាជីវកម្មរហូតដល់ផុតកំណត់នៃវិញ្ញាបនបត្រពន្ធអាជីវកម្មដំបូងរបស់ខ្លួន។ អ្នកស្នើសុំត្រូវបង់ពន្ធដំបូងដោយផ្អែកលើចំនួនទឹកប្រាក់។

- **<u>ការបង្វិលសងប្រាក់ពន្ធ ប្រាក់ពិន័យ ឬការប្រាក់៖</u>**
  *ពន្ធដែលបានប្រមូលខុស។* ការផ្លាស់ប្ដូរតម្រូវឱ្យអ្នកទាមទារដាក់ពាក្យបណ្ដឹងទាមទារក្នុងរយៈពេល 12 ខែ ផ្ទុយពី 15 ខែ គិតចាប់ពីថ្ងៃបានបង់ពន្ធដែលបានប្រមូលខុស ដោយសារកំហុសរបស់ស្មៀន កំហុសខាងគណនេយ្យ ឬគណិតវិទ្យា។

- **<u>ការផ្លាស់ប្ដូរផ្សេងទៀតនៃវិធានការ "T" និងតំណមានប្រយោជន៍៖</u>**
  កម្មវិធីគណនាពន្ធលើចំណូលដុល - [https://ltss.oaklandnet.com/](https://ltss.oaklandnet.com/)
  ក្រមក្រុង Oakland ជំពូកទី 5.02 - Oakland, CA | បណ្ណាល័យ Municode

យើងប្រចាំការនៅទីនេះចាំជួយអ្នក។ ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងមកយើងខ្ញុំតាមលេខ (510) 238-3704។ អ្នកក៏អាចទាក់ទងយើងខ្ញុំតាមរយៈកម្មវិធីជជែកកម្សាន្តផ្ទាល់តាម https://ltss.oaklandnet.com/ ឬអ៊ីមែលតាម BTWebsupport@Oaklandca.gov។

ដើម្បីស្នើសុំលិខិតជូនដំណឹងនេះជាភាសាអេស្ប៉ាញ ចិន វៀតណាម ឬភាសាផ្សេងទៀត សូមទូរសព្ទទៅលេខ (510) 238-3704 ឬផ្ញើអ៊ីមែលទៅ BtWebSupport@oaklandca.gov។ Para solicitar este aviso en español, chino, vietnamita u otro idioma, llame al (510) 238-3704 or BtWebSupport@oaklandca.gov por correo electrónico. **欲索取**此文件的西班牙文, 中文,越南文或其它翻譯本, 請電(510) 238-3704, 或電 BtWebSupport@oaklandca.gov. Để yêu cầu thông báo này bằng tiếng Tây Ban Nha, tiếng Trung Quốc, tiếng Việt hoặc ngôn ngữ khác, vui lòng gọi (510) 238-3704 hoặc email BtWebSupport@oaklandca.gov.

ការពន្យល់ពីអត្រាពន្ធដែលកើនឡើង និងចំនួនទឹកប្រាក់ដែលត្រូវបង់សម្រាប់ប្រភេទ A (ការលក់រាយ) ដែលបង្កើតបានប្រាក់ចំណូលដុលចំនួន $145,000.00៖

| **ប្រសិនបើចំណូលដុលប្រចាំឆ្នាំចំនួន $145,000** | **នោះពន្ធអាជីវកម្មគឺ៖** | **ពន្ធដែលត្រូវបង់** |
|---|---|---|
| ពន្ធលើចំណូលដុលមិនលើសពី $66,666 | $60 | $60.00 |
| ពន្ធលើចំណូលដុលលើសពី $66,666 ប៉ុន្តែមិនលើសពី $1,000,000 | $60 បូក $0.90 ក្នុង $1,000 នៃមួយ ចំណូលដុលប្រចាំឆ្នាំលើសពី $66,666 | $70.50 |
| ពន្ធលើចំណូលដុលលើសពី $1,000,000 ប៉ុន្តែមិនលើសពី $2,500,000 | $900 បូក $1.10 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $1,000,000 | $0.00 |
| ពន្ធលើចំណូលដុលលើសពី $2,500,000 ប៉ុន្តែមិនលើសពី $20,000,000 | $2,550 បូក $1.80 ក្នុង $1,000 នៃ ចំណុលដុលប្រចាំឆ្នាំជាង $2,500,000 | $0.00 |
| ពន្ធលើចំណូលដុលលើសពី $20,000,000 ប៉ុន្តែមិនលើសពី $50,000,000 | $34,050 បូក $2.00 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $20,000,000 | $0.00 |
| ពន្ធលើចំណូលដុលលើសពី $50,000,000 | $94,050 បូក $2.50 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $50,000,000 | $0.00 |
| **ប្រាក់ពន្ធសរុបដែលត្រូវបង់** | | **$130.50** |

ការពន្យល់ពីអត្រាពន្ធដែលកើនឡើង និងចំនួនទឹកប្រាក់ដែលត្រូវបង់សម្រាប់ប្រភេទ B (អាជីវកម្មលក់គ្រឿងឧបភោគបរិភោគ) ដែលបង្កើតបានប្រាក់ចំណូលដុលចំនួន $51,000,500.00៖

| **បើចំណូលដុលប្រចាំឆ្នាំចំនួន $51,000,500** | **នោះពន្ធអាជីវកម្មគឺ៖** | **ពន្ធដែលត្រូវបង់** |
|---|---|---|
| ពន្ធលើចំណូលដុលមិនលើសពី $120,000 | $60 | $60.00 |
| ពន្ធលើចំណូលដុលលើសពី $120,000 ប៉ុន្តែមិនលើសពី $1,000,000 | $60 បូក $0.50 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $120,000 | $440.00 |
| ពន្ធលើចំណូលដុលលើសពី $1,000,000 ប៉ុន្តែមិនលើសពី $2,500,000 | $500 បូក $0.55 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $1,000,000 | $825.00 |
| ពន្ធលើចំណូលដុលលើសពី $2,500,000 ប៉ុន្តែមិនលើសពី $20,000,000 | $1,325 បូក $1.00 ក្នុង $1,000 នៃ ចំណុលដុលប្រចាំឆ្នាំជាង $2,500,000 | $17,500.00 |

| | | |
|---|---|---|
| ពន្ធលើចំណូលដុលលើសពី $20,000,000 ប៉ុន្តែមិនលើសពី $50,000,000 | $18,825 បូក $1.75 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $20,000,000 | $52,500.00 |
| ពន្ធលើចំណូលដុលលើសពី $50,000,000 | $71,325 បូក $2.50 ក្នុង $1,000 នៃ ចំណូលដុលប្រចាំឆ្នាំលើសពី $50,000,000 | $2,501.25 |
| **ប្រាក់ពន្ធសរុបដែលត្រូវបង់** | | **$73,826.25** |